# ស្វែងយល់បន្ថែមអំពី
# ថ្នាំបង្ការជំងឺអុតស្វា

### អំពីថ្នាំបង្ការ៖

នាពេលបច្ចុប្បន្ននេះ ថ្នាំបង្ការប្រភេទ JYNNEOS™ គឺជាថ្នាំបង្ការតែមួយគត់ដែលបានទទួលសិទ្ធិឱ្យប្រើប្រាស់ដោយរដ្ឋបាលចំណីអាហារ និងឱសថ (FDA) សម្រាប់ទប់ស្កាត់ការឆ្លងនៃជំងឺអុតស្វាចំពោះមនុស្សទាំងឡាយ។ ថ្នាំបង្ការប្រភេទនេះបានទទួលការអនុម័តឱ្យប្រើប្រាស់សម្រាប់បុគ្គលដែលមានអាយុចាប់ពី 18 ឆ្នាំឡើងទៅ និងសម្រាប់បុគ្គលដែលមានអាយុក្រោម 18 ឆ្នាំផងដែរ ចំពោះតែករណីពិសេសមួយចំនួនប៉ុណ្ណោះ។ ថ្នាំបង្ការប្រភេទ JYNNEOS មានផ្ទុកមេរោគមានជីវិតមួយប្រភេទដែលមិនអាចបង្កើតខ្លួនទៅជាច្រើនចំណែកនៅក្នុងខ្លួនមនុស្សបានទេ ពោលគឺ វាមិនអាចបង្កឱ្យអ្នកឆ្លងមេរោគនោះ ឬធ្វើឱ្យអ្នកអាចចម្លងមេរោគបន្តបាននោះឡើយ។ ការចាក់ថ្នាំបង្ការប្រភេទនេះត្រូវបានផ្តល់ជូនចំនួនពីរដង ដែលមានគម្លាតរយៈពេល 4 សប្តាហ៍ពីគ្នា។

**ការផ្គត់ផ្គង់ថ្នាំបង្ការប្រភេទ JYNNEOS នៅក្នុងសហរដ្ឋអាមេរិកសម្រាប់ពេលបច្ចុប្បន្ននេះនៅមានកំណត់ ក៏ប៉ុន្តែ មានការរំពឹងថានឹងមានការផ្គត់ផ្គង់ថ្នាំបង្ការនេះបន្ថែមទៀតនៅអំឡុងពេលប៉ុន្មានសប្តាហ៍ និងប៉ុន្មានខែក្រោយនេះ។**

### ការមានសិទ្ធិសម្រាប់ចាក់ថ្នាំបង្ការ៖

ដោយសារតែការផ្គត់ផ្គង់ថ្នាំបង្ការនៅមានកំណត់ ដូចនេះហើយ ក្នុងពេលបច្ចុប្បន្ននេះ នាយកដ្ឋានសុខភាពសាធារណ: (Public Health) កំពុងមានការផ្តល់ជូនការចាក់ថ្នាំបង្ការជំងឺអុតស្វាសម្រាប់ ក្រុមបុគ្គលដែលប្រឈមនឹងហានិភ័យខ្ពស់ ជាក់លាក់មួយចំនួន។ ថ្នាំបង្ការអាចការពារមនុស្សពីការឆ្លងជំងឺអុតស្វាបាន។

**មិនគួរមានការចាក់ថ្នាំបង្ការចំពោះបុគ្គលទាំងឡាយណាដែលមានផ្ទុកជំងឺអុតស្វាហើយ ឬមានចេញសញ្ញា និងរោគសញ្ញានានានៃជំងឺអុតស្វាហើយនោះទេ។**

ចំពោះបុគ្គលទាំងឡាយដែលមានរោគសញ្ញានានានៃជំងឺនេះ គួរតែពិគ្រោះជាមួយនឹងអ្នកផ្តល់សេវាកម្មថែទាំសុខភាពជាប្រចាំរបស់ពួកគេ ឬហៅទៅកាន់លេខ 2-1-1 ប្រសិនបើពួកគេមិនទាន់មានអ្នកផ្តល់សេវាកម្មថែទាំសុខភាពទេ។ លើសពីនេះ បុគ្គលដែលមិនមានអ្នកផ្តល់សេវាកម្មថែទាំសុខភាព ហើយនិង ដែលបានចេញកន្ទួលរមាស់នៅតំបន់ប្រដាប់ភេទ និងតំបន់ទ្វារធំ អាចប្រើប្រាស់សេវាកម្មនានាបានផងដែរនៅឯ គ្លីនិកផ្នែកសុខភាពផ្លូវភេទរបស់សុខភាពសាធារណ: (ដោយចូលទៅកាន់គេហទំព័រ៖ http:// publichealth.lacounty.gov chs SexualHealthClinicSchedule.pdf)។

**សូមស្កេននៅខាងក្រោម ដើម្បីទទួលបានព័ត៌មានថ្មីៗបំផុត អំពីការមានសិទ្ធិចាក់ថ្នាំបង្ការ**

### ផលប៉ះពាល់ផ្សេងៗក្រោយពេលចាក់ថ្នាំបង្ការ៖

មនុស្សភាគច្រើនដែលបានទទួលចាក់ថ្នាំបង្ការប្រភេទ JYNNEOS ហើយ អាចនឹងមានប្រតិកម្មកម្រិតស្រាលតែប៉ុណ្ណោះ ដែលមានដូចជាគ្រុនក្តៅបន្តិចបន្តួច ការអស់កម្លាំង ហើមកូនកណ្តុរ និងឡើងកន្ទួលក្រហម និងរមាស់ជាដើម នៅនឹងកន្លែងដែលបានចាក់ថ្នាំបង្ការនោះ។ ទោះជាយ៉ាងណាក៏ដោយ ពួកគេគួរតែពិគ្រោះជាមួយនឹងអ្នកផ្តល់សេវាកម្មថែទាំសុខភាព អំពីការព្រួយបារម្ភនានារបស់ពួកគេ និងថាតើពួកគេគួរតែទទួលចាក់ថ្នាំបង្ការឬយ៉ាងណា មុនពេលការផ្តល់ជូនថ្នាំបង្ការនោះ។

### ពេលវេលានៃការចាក់ថ្នាំបង្ការ៖

មជ្ឈមណ្ឌលគ្រប់គ្រង និងទប់ស្កាត់ជំងឺឆ្លង (CDC) បានណែនាំឱ្យទទួលចាក់ថ្នាំបង្ការក្នុងអំឡុងពេល 4 ថ្ងៃបន្ទាប់ពីថ្ងៃដែលបានប៉ះពាល់ទៅនឹងមេរោគអុតស្វា ដើម្បីទប់ស្កាត់ការចាប់ផ្តើមឆ្លងនៃជំងឺនោះ។ ប្រសិនបើការទទួលចាក់ថ្នាំបង្ការនោះគឺនៅចន្លោះ ពី 4 ទៅ 14 ថ្ងៃបន្ទាប់ពីថ្ងៃដែលបានប៉ះពាល់ទៅនឹងមេរោគ ការចាក់ថ្នាំបង្ការអាចនឹងកាត់បន្ថយរោគសញ្ញានានានៃជំងឺនោះ ក៏ប៉ុន្តែប្រហែលជាមិនអាចទប់ស្កាត់ការឆ្លងនោះបានទេ។ ប្រព័ន្ធការពារត្រូវបានចាត់ទុកថាបានពេញលេញ គិតចាប់ពីរយ:ពេល 2 សប្តាហ៍បន្ទាប់ពីបានទទួលចាក់ដូសទីពីររួច។ ដោយសារតែការផ្គត់ផ្គង់ថ្នាំបង្ការនៅក្នុងប្រទេសនាពេលបច្ចុប្បន្ននេះនៅមានកំណត់នៅឡើយ ដូចនេះហើយ នាយកដ្ឋានសុខភាពសាធារណ: សម្រេចផ្តល់អាទិភាពចំពោះការចាក់ថ្នាំបង្ការជំងឺអុតស្វាដូសទីមួយជូនដល់បុគ្គលទាំងឡាយដែលមានសិទ្ធិទទួលចាក់ថ្នាំបង្ការទាំងអស់ ឱ្យបានកាន់តែច្រើនតាមដែលអាចធ្វើទៅបានសិន នាពេលនេះ។ នៅពេលណាដែលការផ្គត់ផ្គង់ថ្នាំបង្ការពីរដ្ឋាភិបាលមានច្រើនថែមទៀតនោះ នាយកដ្ឋានសុខភាពសាធារណ: នឹងផ្តល់ជូនការចាក់ដូសទីពីរសម្រាប់អ្នកដែលបានចាក់ដូសដំបូងរួចផងដែរ។

សម្រាប់ព័ត៌មានបន្ថែមអំពីថ្នាំបង្ការជំងឺអុតស្វា សូមយោងទៅលើតារាងព័ត៌មានអំពីថ្នាំបង្ការ (VIS)៖ ថ្នាំបង្ការ (ប្រភេទ JYNNEOS) ជំងឺអុតតូច/អុតស្វា៖ អ្វីដែលអ្នកត្រូវដឹង ដោយចូលទៅកាន់គេហទំព័រ៖ (https://www.cdc.gov/vaccines/hcp/vis/vis-statements/smallpox-monkeypox.pdf)។

**ដោយសារតែព័ត៌មានកំពុងផ្លាស់ប្តូរញឹកញាប់ សូមចូលទៅកាន់គេហទំព័រ សុខភាពសាធារណ:ផ្នែកជំងឺអុតស្វា សម្រាប់ព័ត៌មានថ្មីៗបំផុត ដែលពាក់ព័ន្ធនឹងសិទ្ធិទទួល ហើយនិងការទទួលចាក់ថ្នាំបង្ការ។**

**សម្រាប់ព័ត៌មានបន្ថែមអំពីជំងឺអុតស្វា សូមចូលទៅកាន់គេហទំព័រ៖** ph.lacounty.gov/Monkeypox/

Revised: 7/25/2022 (Cambodian)

County of Los Angeles Public Health